# ព្រះរាជក្រម

នស/រកម/១០០៥/០៣៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារ នៃការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីតំបន់វិនិយោគអាស៊ាន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើពិធីសារនៃការធ្វើវិសោធនកម្មលើ
# កិច្ចព្រមព្រៀងក្របខំណ្ឌស្តីពីតំបន់វិនិយោគអាស៊ាន

មាត្រា ១.-

អនុម័តយល់ព្រមលើពិធីសារនៃការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងក្របខំណ្ឌស្តីពីតំបន់វិនិយោគអាស៊ាន ដែលបានធ្វើ និងចុះហត្ថលេខានៅទីក្រុងហាណូយ ប្រទេសវៀតណាម នាថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

នស/រកម.០៤១០.៤៤០ ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

លេខ ៤២១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុខ តាន់

៣/៣

# ក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីអំពីតំបន់វិនិយោគអាស៊ាន

ទីក្រុងម៉ានីល ថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៩៨

Framework Agreement on the ASEAN Investment Area

Manila, 7 October 1998

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡាំ សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ប្រទេសម៉ាឡេស៊ី សហព័ន្ធមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (តទៅមុខនឹងហៅកាត់ថា "អាស៊ាន") ។

ដោយបញ្ជាក់លើសារសំខាន់នៃនិរន្តរភាពកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍នៅក្នុង រដ្ឋជាសមាជិកទាំងអស់តាមរយៈការប្រឹងប្រែងរួមក្នុងការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងជំរុញពាណិជ្ជកម្មក្នុងរង្វង់អាស៊ាន និងលំហូរវិនិយោគ ដែលមានចែងនៅក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីអំពីការពង្រឹងសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន ដែលបានចុះហត្ថលេខានៅសឹង្ហបុរី នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩២ ។

ដោយយោងទៅលើសេចក្តីសំរេចចិត្តនៃកិច្ចប្រជុំកំពូលលើកទី៥ ដែលបានធ្វើឡើងនៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ១៩៩៥ ស្តីអំពីការបង្កើនវិនិយោគអាស៊ាន (តទៅនេះនឹងហៅកាត់ថា"AIA") ដើម្បីពង្រីកការប្រកួតប្រជែង និងការទាក់ទាញសំរាប់ជំរុញការវិនិយោគដោយផ្ទាល់ ។

ដោយបញ្ជាក់ទៅលើការប្តេជ្ញាចំពោះកិច្ចព្រមព្រៀងឆ្នាំ១៩៨៧ ស្តីអំពីការជំរុញ និងការគាំពារវិនិយោគ និងពិធីសារឆ្នាំ១៩៩៦ ស្តីអំពីការពង្រឹងទំនុកចិត្តរបស់វិនិយោគិន អោយមកធ្វើវិនិយោគក្នុងអាស៊ាន ។

ដោយចាប់អារម្មណ៍ទៅលើសេចក្តីសំរេចចិត្តស្តីអំពីការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងការអនុវត្តន៍គំរោងសហប្រតិបត្តិការឧស្សាហកម្មអាស៊ាន ដើម្បីលើកស្ទួយលំហូរវិនិយោគអោយកាន់តែច្រើនមកក្នុងតំបន់ ។

ដោយទទួលស្គាល់ថា ការវិនិយោគដោយផ្ទាល់គឺជាប្រភពហិរញ្ញវត្ថុយ៉ាងសំខាន់ក្នុងនិរន្តរភាពសេដ្ឋកិច្ចឧស្សាហកម្ម ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យា ដែលជាប្រការអោយមានតំរូវការ ទាក់ទាញ

អោយមានលំហូរវិនិយោគដោយផ្ទាល់អោយកាន់តែខ្លាំងមកក្នុងអាស៊ាន ។

ដោយប្តេជ្ញាអនុវត្តអោយបានសំរេចនូវចក្ខុវិស័យរបស់អាស៊ាន ស្តីអំពីការបង្កើតតំបន់វិនិយោគអាស៊ានប្រកបដោយភាពប្រជែងឈ្នះ តាមរយៈការធ្វើអោយមានបរិស្ថានវិនិយោគសេរី និងតំលាភាពនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១០ និង

ដោយប្រកាន់ភ្ជាប់នៅក្នុងឆន្ទៈថា បណ្តាវិធានការដែលបានឯកភាពគ្នាក្នុងការបង្កើតតំបន់វិនិយោគអាស៊ានប្រកបដោយភាពប្រជែងឈ្នះនៅឆ្នាំ២០១០ នឹងក្លាយទៅជាបច្ច័យឆ្ពោះទៅរកចក្ខុវិស័យរបស់អាស៊ាន ឆ្នាំ២០២០ ។

បានព្រមព្រៀងគ្នាដូចខាងក្រោមនេះ ៖

**មាត្រា១**

**និយមន័យ**

គោលបំណងនៃកិច្ចព្រមព្រៀងនេះ

"វិនិយោគិនអាស៊ាន" មានន័យថា:

(i) ជនជាតិនៃប្រទេសជាសមាជិក ឬ

(ii) នីតិបុគ្គលនៃប្រទេសសមាជិក ។

ដែលធ្វើវិនិយោគទៅក្នុងប្រទេសជាសមាជិក ដទៃទៀត ហើយដែលកម្មសិទ្ធិប្រសិទ្ធិភាពអាស៊ានកើតឡើងដោយសារការបូកសរុប បញ្ចូលនូវកម្មសិទ្ធិរបស់វិនិយោគិនអាស៊ានដទៃទៀត ហើយដែលឆ្លើយតបទៅនឹង សំណូមពររបស់ប្រទេសទទួលវិនិយោគ ក្នុងករណីនៃវិនិយោគនោះ ។

"កម្មសិទ្ធិប្រសិទ្ធិភាពអាស៊ាន" នៃវិនិយោគនៅក្នុងប្រទេសជាសមាជិក មានន័យថា ការកាន់កាប់ដោយអង្គភាពជាតិ ឬអង្គភាពស្របច្បាប់នៃប្រទេសជាសមាជិកនៅក្នុងកិច្ចការវិនិយោគនោះ ។ នៅក្នុងករណីដែលរចនាសម្ព័ន្ធភាគហ៊ុន ឬកម្មសិទ្ធិនៃវិនិយោគិនអាស៊ាន ធ្វើអោយមានការលំបាកក្នុងការបង្កើតរចនាសម្ព័ន្ធកាន់កាប់ផ្តាច់មុខ វិធានការ និងនីតិវិធីនៃការកំណត់កម្មសិទ្ធិប្រសិទ្ធិភាព ដែលរះប្រើប្រាស់ដោយរដ្ឋ

ជាសមាជិក ដែលវិនិយោគិនអាស៊ានចូលទៅធ្វើវិនិយោគនោះ អាចនឹងយកមកប្រើប្រាស់បាន ។ប្រសិន ជាចាំបាច់គណកម្មាធិការសំរបសំរួលកិច្ចការវិនិយោគ អាចនឹងរៀបចំការណែនាំស្តីអំពីការងារនេះ ។

"និតិបុគ្គល" មានន័យថា អង្គភាពនិតិបុគ្គលដែលបានបង្កើតឡើង ឬរៀបចំឡើងស្របតាមច្បាប់នៃ ប្រទេសជាសមាជិក ទោះបីជាដើម្បីរកផលចំណេញឬ មិនរកផលចំណេញ កាន់កាប់ដោយឯកជន ឬដោយរដ្ឋ រួមទាំងសាជីវកម្មដៃគូសហគ្រាសចំរុះ កម្មសិទ្ធិឯកជន ឬសមាគម ។

"វិធានការ" មានន័យថា ច្បាប់ បទបញ្ញត្តិ វិធាន និតិវិធី សេចក្តីសំរេច សកម្មភាពរដ្ឋបាល ឬសកម្មភាព ផ្សេងៗទៀត ដែលជះឥទ្ធិពលមកលើវិនិយោគ ដែលប្រតិបត្តិដោយប្រទេសជាសមាជិក ។

«ជនជាតិ» មានន័យថា បុគ្គលរូបវន្ត ដែលមានសញ្ជាតិនៃប្រទេសជាសមាជិកស្របតាមច្បាប់នៃ ប្រទេសនោះ ។

## មាត្រា២

## ការគ្របដណ្តប់

កិច្ចព្រមព្រៀងនេះគ្របដណ្តប់លើបណ្តាវិនិយោគដោយផ្ទាល់ លើកលែងតែ

(ក) ការវិនិយោគភាគហ៊ុន និង

(ខ) កិច្ចការពាក់ព័ន្ធនឹងការវិនិយោគដែលគ្រប់ដណ្តប់ដោយកិច្ចព្រមព្រៀងអាស៊ានដទៃទៀត ដូច ជាក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងអាស៊ានស្តីពីសេវាកម្ម ។

## មាត្រា៣

## គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះមាន:

(ក) បង្កើតតំបន់វិនិយោគអាស៊ានប្រកបដោយភាពប្រជែងឈ្នះ ដោយមានបរិស្ថានវិនិយោគសេរី និងតំលា ភាពក្នុងចំណោមរដ្ឋជាសមាជិក ដើម្បី :

(i) បង្កើនលំហូរវិនិយោគអោយកាន់តែច្រើនមកក្នុងតំបន់អាស៊ាន ពីប្រភពអាស៊ាន និងមិនមែនអាស៊ាន

(ii) សហការគ្នាជំរុញអាស៊ានអោយទៅជាតំបន់មានការទាក់ទាញវិនិយោគខ្លាំង

(iii) ពង្រីក និងបង្កើនភាពប្រជែងឈ្នះនៃវិស័យសេដ្ឋកិច្ចអាស៊ាន

(iv) កាត់បន្ថយឬលប់បំបាត់ចោលនូវបទបញ្ញត្តិវិនិយោគ និងលក្ខខ័ណ្ឌផ្សេងៗ ដែលជារបាំងដល់លំហូរវិនិយោគ និងអនុវត្តគំរោងវិនិយោគនៅក្នុងអាស៊ាន

(ខ) ដើម្បីធានាថា ការអនុវត្តន៏គោលបំណង ទាំងប៉ុន្មានខាងលើនេះ នឹងចូលជាបច្ច័យឆ្ពោះទៅរកលំហូរវិនិយោគ ដោយសេរីនៅឆ្នាំ២០២០។

## មាត្រា៤

## លក្ខណៈពិសេស

តំបន់វិនិយោគអាស៊ានគឺជាតំបន់ដែលៈ

(ក) កម្មវិធីសហប្រតិបត្តិការ សំរបសំរួលវិនិយោគអាស៊ាន ដែលនឹងបង្កអោយមានកំណើនវិនិយោគទាំងអាស៊ាន និងមិនមែនអាស៊ាន

(ខ) ប្រព្រឹត្តិកម្មជាតិត្រូវផ្តល់អោយវិនិយោគិនអាស៊ាននៅឆ្នាំ២០១០ និងទៅវិនិយោគិនទាំងអស់នៅឆ្នាំ២០២០ តែជាកម្មវត្ថុនៃការលើកលែង ដែលផ្តល់អោយនៅក្រោមកិច្ចព្រមព្រៀងនេះ

(គ) ឧស្សាហកម្មទាំងអស់ នឹងបើកចំហអោយវិនិយោគ ដោយវិនិយោគិនអាស៊ាននៅឆ្នាំ២០១០ និងចំពោះវិនិយោគិនទាំងអស់នៅឆ្នាំ២០២០ តែជាកម្មវត្ថុនៃការលើកលែង ដែលផ្តល់អោយនៃកិច្ចព្រមព្រៀងនេះ

(ឃ) វិស័យធុរៈកម្មមានតួនាទីចំបង ក្នុងកិច្ចសហប្រតិបត្តិការលើការងារពាក់ព័ន្ធនឹងការវិនិយោគក្នុងអាស៊ាន និង

(ង) មានលំហូរមូលធន កំលាំងពលកម្មជំនាញ និងឯកទេស និងបច្ចេកវិទ្យាក្នុងចំណោមប្រទេសជាសមាជិក។

## មាត្រា៥

## ភាតព្វកិច្ចទូទៅ

ដើម្បីអនុវត្តអោយបានសំរេចនូវគោលបំណងដូចមានចែងនៅក្នុងមាត្រា៣ប្រទេសជាសមាជិកត្រូវៈ

(ក) ធានាថា វិធានការ និងកម្មវិធីត្រូវប្រតិបត្តិ ដោយយុត្តិធម៌ និងឈរលើមូលដ្ឋានផលប្រយោជន៍ទៅវិញទៅមក

(ខ) អនុវត្តនូវវិធានការសមស្រប ដើម្បីធានាតំលាភាព និងភាពរលូនក្នុងការប្រតិបត្តិ និងបកស្រាយច្បាប់វិនិយោគ បទបញ្ញត្តិ និងនិតិវិធីរដ្ឋបាល ដើម្បីបង្កើត និងរក្សានូវរបបវិនិយោគ ដែលអាចប្រមើលមើលនៅក្នុងអាស៊ាន

(គ) ចាប់ផ្តើមអនុវត្តដំណើរការនៃការសំរួល ជំរុញ និងសេរីភាវូបនីយកម្ម ដែលនឹងចូលរួមជាបន្តបន្ទាប់ សំរេចនូវគោលបំណង នៃការបង្កើតបរិស្ថានវិនិយោគអោយមានលក្ខណៈសេរី និងតំលាភាព

(ឃ) ចាត់វិធានការសមស្រប ដើម្បីពង្រឹងបរិស្ថានទាក់ទាញវិនិយោគនៅក្នុងប្រទេសជាសមាជិក សំរាប់លំហូរវិនិយោគផ្ទាល់ និង

(ង) ចាត់វិធានការសមស្រប ដែលអាចធ្វើទៅបាន ដើម្បីធានាការសង្កេត លើការអនុវត្តន៍បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ដោយរដ្ឋអំណាចតំបន់ និងមូលដ្ឋាន និងអាជ្ញាធរដែនដី ។

## មាត្រា៦
## កម្មវិធី និងផែនការសកម្មភាព

១- ដើម្បីអនុវត្តនូវកាតព្វកិច្ច ក្រោមកិច្ចព្រមព្រៀងនេះ ប្រទេសជាសមាជិកត្រូវលើកឡើង នូវការអភិវឌ្ឍន៍ និង អនុវត្តរួមនៃកម្មវិធីដូចតទៅ:

(ក) កម្មវិធីសហប្រតិបត្តិការ និងសំរួលដូចមានចែងក្នុងកម្មវិធីទី ១

(ខ) កម្មវិធីជំរុញ និងផ្សព្វផ្សាយ ដូចមានលើកឡើងក្នុងកម្មវិធីទី ២ និង

(គ) កម្មវិធីសេរីភាវូបនីយកម្ម ដូចមានចែងក្នុងកម្មវិធីទី ៣ ។

២-ប្រទេសជាសមាជិកត្រូវបញ្ជូនផែនការសកម្មភាពសំរាប់អនុវត្តបណ្តាកម្មវិធីនៅក្នុងកថាខ័ណ្ឌទី១ ទៅក្រុមប្រឹក្សា AIA ដែលបង្កើតឡើងក្រោមមាត្រា១៨នៃកិច្ចព្រមព្រៀងនេះ ។

៣-ផែនការសកម្មភាព នឹងត្រូវពិនិត្យសារឡើងវិញនៅក្នុងពេលពីរឆ្នាំម្តង ដើម្បីធានាថាគោលបំណងនៃកិច្ចព្រមព្រៀងនេះ នឹងបានសំរេច ។

## មាត្រា៧
## ការបើកចំហរឧស្សាហកម្ម និង ប្រព្រឹត្តិកម្មជាតិ

១-ជាកម្មវត្ថុនៃលក្ខខ័ណ្ឌនិងការកំណត់ខាងក្រោមនេះ ប្រទេសជាសមាជិកនីមួយៗ ត្រូវ

ក- បើកចំហរឧស្សាហកម្មរបស់ខ្លួនជាបន្ទាន់សំរាប់ការវិនិយោគ ចំពោះវិនិយោគិនអាស៊ាន

ខ- ផ្តល់ជាបន្ទាន់ដល់ វិនិយោគិន និងការវិនិយោគនៃប្រទេសសមាជិកដទៃទៀតលើវិធានការ ដែលពាក់ព័ន្ធនឹងការវិនិយោគដែលរួមមាន តែមិនកំរិតត្រឹម ការអនុញ្ញាត្តិ ការបង្កើតការទិញយក ការពង្រីក ការគ្រប់គ្រងការប្រតិបត្តិ និងការរំសាយ វិនិយោគ នូវប្រព្រឹត្តិកម្មជាតិ ដែលមានលក្ខណៈប្រសើរ មិនតិចជាងអ្វី ដែលផ្តល់អោយវិនិយោគិន និងការវិនិយោគរបស់ខ្លួនឡើយ ("ប្រព្រឹត្តិកម្មជាតិ") ។

២- ប្រទេសជាសមាជិកនីមួយៗត្រូវផ្តល់បញ្ជីលើកលែងបណ្តោះអាសន្ន និងបញ្ជីមានវិសេសិតភាព ប្រសិនបើមាន ក្នុងកំឡុង៦ខែ ក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។ បញ្ជីទាំងនេះគឺជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ។ ក្នុងករណីដែលប្រទេសជាសមាជិកណាមួយ យោងតាមមូលហេតុសមស្រប មិនអាចផ្តល់បញ្ជីទាំងនោះក្នុងកំឡុងពេលដែលបានកំណត់នោះ ប្រទេសនោះអាចស្នើសុំពន្យារពេល ពីក្រុមប្រឹក្សា AIA ។

៣- បញ្ជីលើកលែងបណ្តោះអាសន្នត្រូវពិនិត្យឡើងវិញ ក្នុងរយៈពេលពីរឆ្នាំម្តង ហើយត្រូវលុបបំបាត់អោយអស់នៅឆ្នាំ២០១០ ដោយប្រទេសជាសមាជិកទាំងអស់ លើកលែងតែសាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងសហព័ន្ធមីយ៉ាន់ម៉ា ។ សាធារណរដ្ឋសង្គមនិយមវៀតណាមត្រូវលុបបំបាត់បញ្ជីលើកលែងបណ្តោះអាសន្ននៅឆ្នាំ២០១៣ ហើយសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងសហព័ន្ធមីយ៉ាន់ម៉ា ត្រូវលុបបំបាត់បញ្ជីលើកលែងបណ្តោះអាសន្នរបស់គេនៅឆ្នាំ២០១៥ ។

៤-បញ្ជីវិសេសិតភាព ត្រូវពិនិត្យសារឡើងវិញដោយប្រទេសជាសមាជិកទាំងអស់នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៣ ឬក៏ក្នុងចន្លោះរយៈពេលនោះស្របតាមការសំរេចរបស់ក្រុមប្រឹក្សា AIA ។

## មាត្រា៨

## ឋានៈជាប្រទេសទទួលការអនុគ្រោះបំផុត

១- ជាកម្មវត្ថុនៃមាត្រា ៧ និង ៩ ប្រទេសជាសមាជិកនីមួយៗត្រូវផ្តល់ជាបន្ទាន់ និងគ្មានលក្ខខ័ណ្ឌដល់វិនិយោគិន និងការវិនិយោគនៃប្រទេសជាសមាជិកដទៃទៀតនូវប្រព្រឹត្តិកម្ម ដែលមានលក្ខណៈប្រសើរមិនតិចជាងអ្វីដែលបានផ្តល់ដល់វិនិយោគិន និងការវិនិយោគនៃប្រទេសជាសមាជិកផ្សេងទៀត លើរាល់វិធានការ

ពាក់ព័ន្ធនឹងការវិនិយោគរួមមាន តែមិនកំរិតត្រឹមការអនុញ្ញាត ការបង្កើត ការទិញយក ការពង្រីក ការគ្រប់គ្រង ការប្រតិបត្តិ និងការរំសាយវិនិយោគ ។

២- ពាក់ព័ន្ធនឹងការវិនិយោគនានា ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ ការផ្តល់ការអនុគ្រោះក្រោមកិច្ចព្រមព្រៀងបច្ចុប្បន្ន ឬអនាគត ដែលប្រទេសជាសមាជិកជាភាគីជាប់កិច្ចសន្យា ត្រូវតែផ្តល់ជូនទៅប្រទេសជាសមាជិកដទៃទៀតដោយឈរលើមូលដ្ឋានប្រទេសដែលទទួលការអនុគ្រោះបំផុត។

៣- តំរូវការដូចមានចែងក្នុងកថាខ័ណ្ឌទី២ មិនត្រូវអនុវត្តចំពោះកិច្ចព្រមព្រៀងបច្ចុប្បន្ន ដែលបានជូនដំណឹងដោយប្រទេសជាសមាជិក ទៅក្រុមប្រឹក្សា AIA ក្នុងកំឡុងពេល៦ខែ ក្រោយការចុះហត្ថលេខានៃកិច្ចព្រមព្រៀងនេះ ។

៤- គ្មានប្រការណាមួយក្នុងកថាខ័ណ្ឌទី១ ដែលរារាំងប្រទេសជាសមាជិកពីការរៀបចំប្រព្រឹត្តិកម្មពិសេស ឬក៏ឧត្តមភាពនានាចំពោះប្រទេសភាគី នៅក្រោមកិច្ចព្រមព្រៀងកំណើនត្រីកោណ និងអនុតំបន់រវាងប្រទេសជាសមាជិកឡើយ ។

## មាត្រា៩
## ការមិនទទួលយកប្រព្រឹត្តិកម្មឋានៈជាប្រទេសទទួលការអនុគ្រោះបំផុត

១- ក្នុងករណីដែលប្រទេសជាសមាជិកមួយមិនទាន់អាចបញ្ចូលវិធានការឬឧស្សាហកម្មក្រោមមាត្រា៨(១) ឬ៩(១) នៃកិច្ចព្រមព្រៀងនេះ ហើយប្រទេសជាសមាជិកមួយទៀតបានផ្តល់សម្បទាន ពាក់ព័ន្ធនឹងវិធានការ ឬឧស្សាហកម្មទាំងនោះ ប្រទេសជាសមាជិកទី១ ត្រូវព្យួរសិទ្ធិរបស់ខ្លួនក្នុងការទទួលយកសម្បទានលើវិធានការ ឬឧស្សាហកម្មនោះ។ ក៏ប៉ុន្តែ បើប្រទេសជាសមាជិកដែលបានផ្តល់សម្បទាននោះ មានឆន្ទៈមិនទទួលការព្យួរនោះ ប្រទេសជាសមាជិកទីមួយខាងលើ ក៏នៅតែអាចទទួលសម្បទានដែរ ។

២- ដោយយោងទៅលើការចូលរួមក្នុងអាស៊ាននាពេលចុងក្រោយនេះ សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងសហព័ន្ធមីយ៉ាន់ម៉ា បញ្ញត្តិនៃកថាខ័ណ្ឌទី១ នៃមាត្រានេះ អាចអនុវត្តចំពោះសាធារណរដ្ឋសង្គមនិយមវៀតណាមក្នុងរយៈពេល៣ឆ្នាំ ហើយនិងចំពោះសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងសហព័ន្ធមីយ៉ាន់ម៉ាក្នុងរយៈពេល៥ឆ្នាំ រាប់ចាប់ពីពេល ដែលកិច្ចព្រមព្រៀង នេះចូលជាធរមាន។

## មាត្រា១០
## ការកែលំអរកម្មវិធី ឧបសម្ព័ន្ធ និងផែនការសកម្មភាព

១- ការកែប្រែណាមួយចំពោះកម្មវិធីទី I ,II និងផែនការសកម្មភាព ត្រូវតែជាកម្មវត្ថុនៃការឯកភាពរបស់គណៈកម្មាធិការសំរបសំរួលកិច្ចការវិនិយោគ (CCI) ដែលបង្កើតឡើងតាមមាត្រា១៦(៤) នៃកិច្ចព្រមព្រៀងនេះ ។

២- ការកែប្រែណាមួយ ឬដកហូតចេញការប្តេជ្ញានៅក្នុងកម្មវិធីទី III នៃសកម្មភាព និងឧបសម្ព័ន្ធ ត្រូវតែជាកម្មវត្ថុនៃការចំណាប់អារម្មណ៍របស់ក្រុមប្រឹក្សា AIA ស្របតាមបញ្ញត្តិនៃពិធីសារអាស៊ានស្តីអំពីនីតិវិធីផ្តល់ដំណឹង ។

## មាត្រា១១
## តំលាភាព

១-ប្រទេសជាសមាជិកនីមួយៗត្រូវជូនទៅក្រុមប្រឹក្សា AIA តាមរយៈការបោះពុម្ព ឬមធ្យោបាយផ្សេងៗទៀត នូវវិធានការ ច្បាប់ បទបញ្ញត្តិ និងគោលការរដ្ឋបាល ដែលពាក់ព័ន្ធចំពោះ ឬមានឥទ្ធិពល ទៅលើការ ប្រតិបត្តិនៃកិច្ចព្រមព្រៀងនេះ ។ ប្រការនេះក៏អនុវត្តចំពោះកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលពាក់ព័ន្ធនឹង ឬមានឥទ្ធិពលចំពោះការវិនិយោគ ដែលប្រទេសជាសមាជិក ជាប្រទេសហត្ថលេខី ។

២- ប្រទេសជាសមាជិកនីមួយៗត្រូវជូនពត៌មានជាបន្ទាន់ ឬក៏យ៉ាងហោចណាស់មួយឆ្នាំម្តងទៅក្រុមប្រឹក្សា AIA ស្តីអំពីការបង្កើតច្បាប់ថ្មី ឬការកែប្រែច្បាប់បច្ចុប្បន្ន បទបញ្ញត្តិ និងគោលការរដ្ឋបាល ដែលមានឥទ្ធិពលមកលើកិច្ចការវិនិយោគ ឬការប្តេជ្ញានានានៅក្រោមកិច្ចព្រមព្រៀងនេះ ។

៣-គ្មានប្រទេសណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ដែលទាមទារអោយប្រទេសសមាជិកផ្តល់ពត៌មានសំងាត់ ដែលការផ្សព្វផ្សាយ នឹងបង្កអោយមានការរាំងស្ទះក្នុងការអនុវត្តន៍ច្បាប់ ឬក៏ផ្ទុយពីនោះប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ឬក៏អាចនាំអោយមានការប៉ះពាល់ដល់ផលប្រយោជន៍ពាណិជ្ជកម្មនៃក្រុមហ៊ុនណាមួយ ជាសាធារណៈ ឬជាឯកជន ។

## មាត្រា១២

## កិច្ចព្រមព្រៀងផ្សេងៗទៀត

១- ប្រទេសជាសមាជិកបានបញ្ជាក់ជំហររបស់ខ្លួនលើសិទ្ធិ និងកាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀងអាស៊ាន ឆ្នាំ១៩៨៧ ស្តីអំពីការជំរុញ និងការការពារវិនិយោគ និងពិធីសារឆ្នាំ១៩៩៦។ ក្នុងករណីដែលកិច្ចព្រមព្រៀងនេះធ្វើអោយប្រសើរ ឬក៏ពង្រឹងបញ្ញត្តិនៃកិច្ចព្រមព្រៀង និងពិធីសារ ដែលបានលើកឡើង បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ នឹងត្រូវបានយកមកអនុវត្ត។

២- កិច្ចព្រមព្រៀង ឬក៏សកម្មភាពណាមួយ ដែលអនុវត្តក្រោមកិច្ចព្រមព្រៀងនេះ នឹងមិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ច នៃប្រទេសជាសមាជិក ដែលជាភាគីជាប់កិច្ចសន្យា នៃកិច្ចព្រមព្រៀងបច្ចុប្បន្នឡើយ។

៣- គ្មានប្រការណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ដែលប៉ះពាល់ដល់សិទ្ធិរបស់ប្រទេសជាសមាជិក ក្នុងការចូលរួមក្នុងកិច្ចព្រមព្រៀងផ្សេងៗ ដែលមិនផ្ទុយនឹងគោលការណ៍ គោលបំណង និងលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ។

### មាត្រា១៣
### ការលើកលែងទូទៅ

ជាកម្មវត្ថុនៃតំរូវការដែលថា បណ្តាវិធានការ ដែលមិនអាចអនុវត្តបាន នៅក្នុងមូលហេតុ ដែលអាចឈានទៅដល់តុលាការ ឬការរើសអើងដោយអយុត្តិធម៌រវាងប្រទេសដែលមានលក្ខខ័ណ្ឌទាំងនោះ ឬការកំរិតលំហូរវិនិយោគ គ្មានប្រការណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ដែលអាចរារាំងដល់ការអនុម័ត ឬការអនុវត្តន៍ដោយប្រទេសជាសមាជិក នូវបណ្តាវិធានការខាងក្រោមនេះ:

(ក) ការចាំបាច់ក្នុងការការពារសីលធម៌សាធារណៈ ឬដើម្បីរក្សារបៀបរៀបរយសាធារណៈ

(ខ) ការចាំបាច់ក្នុងការការពារជីវិត ឬសុខភាពមនុស្ស សត្វ ឬរុក្ខជាតិ

(គ) ការចាំបាច់ដើម្បីធានាភាពស្របច្បាប់ ឬបទបញ្ញត្តិផ្សេងៗដែលមិនស្របគ្នានឹងបញ្ញត្តិមួយចំនួននៃកិច្ចព្រមព្រៀងនេះ ដែលរួមមាន:

(i) ការការពារទល់នឹងការភូតភរ និងក្លែងបន្លំ ឬការពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង វិនិយោគ ដែលកំពុងស្ថិតជាធរមាន។

(ii) ការការពារទល់នឹងការសំងាត់(ឯកជន)របស់បុគ្គលពាក់ព័ន្ធនឹងការរៀបចំ និងផ្សព្វផ្សាយទិន្នន័យផ្ទាល់ខ្លួន និងការការពារការសំងាត់នៃកំណត់ហេតុ និងគណនីផ្ទាល់ខ្លួន។

(iii) សុវត្ថិភាព ។

(ឃ) មានបំណងធានានូវសមភាព ឬការលើក និងប្រមូលពន្ធអោយមានប្រសិទ្ធិភាព ពាក់ព័ន្ធនឹងការវិនិយោគ ឬវិនិយោគិន នៃប្រទេសជាសមាជិក ។

## មាត្រា១៤
## វិធានការការពារបន្ទាន់

១- ជាលទ្ធផលនៃការអនុវត្តន៍កម្មវិធីសេរីភាវូបនីយកម្ម ក្រោមកិច្ចព្រមព្រៀងនេះ បើសិនជាប្រទេសជាសមាជិកណាមួយទទួលរងគ្រោះ ឬការគំរាមកំហែងដោយការខូចខាតធ្ងន់ធ្ងរនោះ ប្រទេសជាសមាជិកនោះអាចលើកឡើងនូវវិធានការការពារបន្ទាន់ ឬពន្យារពេល ហើយក្នុងពេលដែលចាំបាច់អាចនឹងការពារ ឬស្តារនូវការខូចខាតទាំងនោះ ។ វិធានការដែលលើកឡើងនេះ ត្រូវតែជាបញ្ញត្តិហើយមិនមានការរើសអើង ។
២- នៅក្នុងករណី ដែលវិធានការការការពារបន្ទាន់ត្រូវបានលើកឡើងស្របតាមមាត្រានេះពត៌មានស្តីពីវិធានការនោះត្រូវបញ្ជូនទៅក្រុមប្រឹក្សា AIA ក្នុងកំឡុងពេល១៤ថ្ងៃក្រោយពេលវិធានការនោះបានលើកឡើង ។
៣- ក្រុមប្រឹក្សា AIA ត្រូវបានកំណត់ការអោយនិយមន័យទៅលើពាក្យខូចខាតធ្ងន់ធ្ងរ ឬការគំរាមកំហែងអោយមានការខូចខាតធ្ងន់ធ្ងរ និងនិតិវិធីនៃការលើកឡើង វិធានការការពារបន្ទាន់ស្របតាមមាត្រានេះ ។

## មាត្រា១៥
## វិធានការការពារតុល្យភាពជញ្ជីងទូទាត់

១- នៅក្នុងករណីដែលមានបញ្ហាធ្ងន់ធ្ងរផ្នែកតុល្យភាពជញ្ជីងទូទាត់ និងការលំបាកផ្នែកហិរញ្ញវត្ថុក្រៅប្រទេស ឬការគំរាមកំហែង ដែលស្តែងចេញពីបញ្ហាអស់ទាំងនោះ ប្រទេសជាសមាជិកអាចអនុម័ត ឬរក្សានូវការកំរិតលើការវិនិយោគ ដែលប្រទេសជាសមាជិកនោះអាចធ្វើការប្តេជ្ញាចិត្ត រួមទាំងការទូទាត់ ឬការផ្ទេរសាច់ប្រាក់កិច្ចសន្យានានា ដែលពាក់ព័ន្ធនឹងការប្តេជ្ញាចិត្តទាំងនោះ ។ គេទទួលស្គាល់ថាមានសំពាធជាក់ស្តែងទៅលើតុល្យភាពជញ្ជីងទូទាត់ នៃប្រទេសជាសមាជិក នៅក្នុងដំណាក់កាលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ឬសេដ្ឋកិច្ចអន្តរកាល ដែលបង្កអោយមានការចាំបាច់ក្នុងការកំរិតនានា ដើម្បីធានាការរក្សាហិរញ្ញវត្ថុបំរុងក្នុងកំរិតមួយដែលឆ្លើយតបនឹងការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច ឬសេដ្ឋកិច្ចអន្តរកាល ។

២- ក្នុងករណីដែលវិធានការការពារតុល្យភាពជញ្ជីងទូទាត់ត្រូវបានលើកឡើងស្របតាមមាត្រានេះ កំណត់បង្ហាញស្តីពីវិធានការទាំងនោះត្រូវផ្តល់ជូនទៅក្រុមប្រឹក្សា AIA ក្នុងកំឡុងពេល១៤ថ្ងៃក្រោយពេល ដែលវិធានការទាំងនោះបានលើកឡើង ។

៣- បណ្តាវិធានការដែលយោងតាមកថាខ័ណ្ឌទី១

(ក) មិនត្រូវមានការរើសអើងក្នុងចំណោមប្រទេសជាសមាជិក

(ខ) ត្រូវតែស្របគ្នានឹងមាត្រានៃកិច្ចព្រមព្រៀងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

(គ) ត្រូវជៀសវៀងការខូចខាតមិនចាំបាច់នានា ចំពោះពាណិជ្ជកម្ម សេដ្ឋកិច្ច និងផលប្រយោជន៍ហិរញ្ញវត្ថុ នៃប្រទេសជាសមាជិកណាមួយ ។

(ឃ) មិនត្រូវជ្រុលលើភាពចាំបាច់ក្នុងការចាត់ចែងស្ថានភាពដូចមានចែងក្នុងកថាខ័ណ្ឌទី១ និង

(ង) ត្រូវតែជាវិធានការបណ្តោះអាសន្ន ហើយនឹងត្រូវលុបបំបាត់ចោលអោយអស់នៅពេលស្ថានភាព ដែលចែងក្នុងកថាខ័ណ្ឌទី១ មានលក្ខណៈប្រសើរឡើងវិញ ។

៤- ប្រទេសសមាជិក ដែលអនុម័តវិធានការជញ្ជីងទូទាត់ ត្រូវចាប់ផ្តើមពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា AIA និងប្រទេសសមាជិកដទៃទៀត ក្នុងអំឡុងពេល៩០ថ្ងៃ ចាប់តាំងពីថ្ងៃជូនដំណឹង ដើម្បីពិនិត្យសារឡើងវិញ លើវិធានការជញ្ជីងទូទាត់ ដែលបានអនុម័តនោះ ។

៥- ក្រុមប្រឹក្សា AIA ត្រូវកំណត់វិធានការ ដែលអនុវត្តចំពោះនិតិវិធីនានានៅក្រោមមាត្រានេះ ។

## មាត្រា១៦
## ការរៀបចំស្ថាប័ន

១-រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានត្រូវបង្កើតក្រុមប្រឹក្សា តំបន់វិនិយោគអាស៊ាន (តទៅនេះនឹងហៅកាត់ថា ក្រុមប្រឹក្សា"AIA") ដែលមានសមាសភាពរដ្ឋមន្ត្រីទទួលបន្ទុកការវិនិយោគ និងអគ្គលេខាធិការអាស៊ាន ក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។ ថ្នាក់ដឹកនាំភ្នាក់ងារវិនិយោគអាស៊ានត្រូវចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សា AIA ។

២- ស្របគ្នានឹងមាត្រា២១ នៃកិច្ចព្រមព្រៀងនេះ ក្រុមប្រឹក្សា AIA ត្រូវបង្កើតឡើងនៅពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

៣-ក្រុមប្រឹក្សា AIA ត្រូវគ្រប់គ្រង សំរបសំរួល និងពិនិត្យលើការអនុវត្តន៍កិច្ចព្រមព្រៀងនេះ និងជួយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានរាល់ការដែលពាក់ព័ន្ធនឹងកិច្ចការនេះ ។

៤- ដើម្បីបំពេញតួនាទីរបស់ខ្លួន ក្រុមប្រឹក្សា AIA ត្រូវបង្កើតគណៈកម្មាធិការសំរបសំរួលកិច្ចការវិនិយោគ CCI ដែលមានសមាសភាពមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកកិច្ចការវិនិយោគ និងមន្ត្រីជាន់ខ្ពស់មកពីស្ថាប័ននានារបស់រដ្ឋាភិបាល ។

៥- គណៈកម្មាធិការសំរបសំរួលវិនិយោគត្រូវធ្វើរបាយការណ៍ទៅក្រុមប្រឹក្សា AIA តាមរយៈឧត្តមមន្ត្រីសេដ្ឋកិច្ច ។

៦- លេខាធិការដ្ឋានអាស៊ាន គឺជាលេខាធិការដ្ឋានសំរាប់ក្រុមប្រឹក្សា AIA និងគណៈកម្មាធិការសំរបសំរួលកិច្ចការវិនិយោគ ។

## មាត្រា១៧
## ដំណោះស្រាយវិវាទ

១- ពិធីសារស្តីអំពីយន្តការដំណោះស្រាយវិវាទ សំរាប់អាស៊ាន អាចប្រើបានចំពោះរាល់បញ្ហាពាក់ព័ន្ធទៅនឹងការ វិវាទនានា ដែលកើតមានឡើងពីមតិផ្ទុយគ្នារវាងប្រទេសសមាជិក ពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តនៃកិច្ចព្រមព្រៀងនេះ ឬការរៀបចំណាមួយ ដែលកើតឡើងពីកិច្ចព្រមព្រៀងនេះ។

២- ប្រសិនបើចាំបាច់ យន្តការដំណោះស្រាយវិវាទពិសេសមួយ អាចត្រូវបង្កើតឡើងសំរាប់គោលដៅនៃកិច្ចព្រមព្រៀងនេះ ដែលនឹងក្លាយជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា១៨
## វិសោធនកម្ម

ការកែប្រែណាមួយទៅលើកិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងដោយមានការព្រមព្រៀងជាកុងសង់ស៊ុស ហើយនឹងចូលជាធរមានក្រោយការតំកល់លិខិតុបករណ៍សច្ចាប័ន ឬការទទួលលិខិតនោះ ដោយរដ្ឋាភិបាលម្ចាស់ហត្ថលេខី នៅអគ្គលេខាធិការអាស៊ាន។

## មាត្រា១៩
## កិច្ចព្រមព្រៀង ឬ ការរៀបចំបន្ថែម

កម្មវិធី ផែនការសកម្មភាព ឧបសម្ព័ន្ធ និងការរៀបចំ ឬកិច្ចព្រមព្រៀងនានា ដែលកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ ត្រូវតែជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា២០
## ការចូលរួមរបស់សមាជិកថ្មី

សមាជិកថ្មីរបស់អាស៊ានត្រូវចូលរួមក្នុងកិច្ចព្រមព្រៀងនេះ តាមកាលបរិច្ឆេទ និងលក្ខខ័ណ្ឌ ដែលឯកភាពគ្នា រវាងសមាជិកថ្មី និងប្រទេសម្ចាស់ហត្ថលេខី នៃកិច្ចព្រមព្រៀងនេះ ហើយត្រូវតំកល់ លិខិតុបករណ៍ចូលរួមនៅអគ្គលេខាធិការអាស៊ាន ។

## មាត្រា២១
## អវសានបញ្ញត្តិ

១- កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាន ក្រោយការតំកល់លិខិតុបករណ៍ សច្ចាប័ន ឬទទួលស្គាល់ដោយរដ្ឋាភិបាលម្ចាស់ ហត្ថលេខីជាមួយនឹងអគ្គលេខាធិការអាស៊ាន។ រដ្ឋាភិបាលម្ចាស់ហត្ថលេខីត្រូវតំកល់លិខិតុបករណ៍ ផ្តល់សច្ចាប័ន ឬការទទួលស្គាល់ក្នុងកំឡុងពេល ៦ខែ ក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

២- កិច្ចព្រមព្រៀងនេះត្រូវតំកល់ទុកដោយអគ្គលេខាធិការអាស៊ាន ដែលត្រូវបញ្ជូនច្បាប់ចំលងត្រឹមត្រូវមួយច្បាប់ ទៅប្រទេសសមាជិកនិមួយៗ ។

ដើម្បីជាសក្ខីភាព ម្ចាស់ហត្ថលេខា ដែលបានទទួលអំណាចត្រឹមត្រូវពីរដ្ឋាភិបាលរបស់ខ្លួន បានចុះហត្ថលេខាលើក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីអំពីតំបន់វិនិយោគអាស៊ាន។

ធ្វើនៅមានីល ហ្វីលីពីនថ្ងៃទី ៨ ខែតុលាឆ្នាំ១៩៩៨ ចំនួនមួយច្បាប់ជាភាសាអង់គ្លេស ។

តំណាងរដ្ឋាភិបាលប្រ៊ុយណេដារូសាឡាំ

តំណាងរដ្ឋាភិបាល សាធារណរដ្ឋឥណ្ឌូនេស៊ី

តំណាងរដ្ឋាភិបាល សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

តំណាងរដ្ឋាភិបាល ម៉ាឡេស៊ី

តំណាងរដ្ឋាភិបាល សហព័ន្ធមីយ៉ាន់ម៉ា

តំណាងរដ្ឋាភិបាល សាធារណរដ្ឋហ្វីលីពីន

តំណាងរដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី

តំណាងរដ្ឋាភិបាល ព្រះរាជាណាចក្រថៃឡង់ដ៏

តំណាងរដ្ឋាភិបាល សាធារណរដ្ឋសង្គមនិយមវៀតណាម

ឧបសម្ព័ន្ធ I

## ក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីពីតំបន់វិនិយោគអាស៊ាន (AIA)

## កម្មវិធីសហប្រតិបត្តិការ និងសម្របសម្រួល

ពាក់ព័ន្ធនឹងកម្មវិធីសហប្រតិបត្តិការ និងសម្របសម្រួលប្រទេសសមាជិកត្រូវ:

(ក) ដូចផ្តើមគំនិតផ្ទាល់ខ្លួនដើម្បី :

(i) បង្កើនតំលាភាពអំពីរបបការវិនិយោគនៃប្រទេសសមាជិក បទបញ្ញត្តិ នយោបាយ និងនីតិវិធីតាមការបោះពុម្ពពត៌មានទាំងនោះ ជាអចិន្ត្រៃយ៍ ហើយធ្វើពត៌មានទាំងនោះអោយទទួលបានទូលំទូលាយ ។

(ii) ធ្វើសញ្ញកម្ម និងពិនិត្យ នីតិវិធីនៃការដាក់ពាក្យ និងការឯកភាពលើគំរោងវិនិយោគគ្រប់ករិត និង

(iii) ពង្រីកចំនួនកិច្ចព្រមព្រៀងទ្វេភាគីស្តីអំពីការជៀសវាងយកពន្ធត្រួតគ្នា ចំណោមប្រទេសសមាជិក ។

(ខ) រួមគ្នាផ្តើមគំនិតដើម្បី:

(i) បង្កើនទិន្នន័យឧស្សាហកម្មអាស៊ាន និងធនាគារបច្ចេកទេសអាស៊ាន

(ii) បង្កើនទិន្នន័យអាស៊ានដើម្បីពង្រឹងលំហូរពត៌មាន និងទិន្នន័យវិនិយោគអាស៊ាន ស្តីអំពីកាលានុវត្តភាពវិនិយោគក្នុងអាស៊ាន ។

(iii) ជំរុញសម្ព័ន្ធភាពវិស័យសាធារណៈ និងឯកជន តាមរយៈការសន្ទនាជាប្រចាំជាមួយនឹងសហគមន៍អាជីវកម្មអាស៊ាន និងអង្គការអន្តរជាតិដទៃទៀត ដើម្បីរកសញ្ញាណ នៃរបាំងនៅក្នុង និងក្រៅអាស៊ាន និងស្នើឡើងនូវនយោបាយ ដើម្បីកែលំអរបរិស្ថានវិនិយោគអាស៊ាន ។

(iv) រកសញ្ញាណនៃវិស័យគោលដៅសំរាប់ សហប្រតិបត្តិការបច្ចេកទេស ដូចជា ការអភិវឌ្ឍន៍ធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ ឧស្សាហកម្មគាំទ្រ សហគ្រាសខ្នាតតូច និងមធ្យម ពត៌មានបច្ចេកវិទ្យា បច្ចេកវិទ្យាឧស្សាហកម្ម ស្រាវ

ស្រាវ ដើម្បីអភិវឌ្ឍន៍ និងការប្រឹងប្រែងសហប្រតិបត្តិការក្នុងអាស៊ាន និងអង្គការអន្តរជាតិនានា ដែលចូលរួមក្នុងសហប្រតិបត្តិការបច្ចេកទេស ។

(v) ពិនិត្យ និងកែលំអ តាមភាពចាំបាច់ នូវកិច្ចព្រមព្រៀងអាស៊ានស្តីអំពីការជំរុញវិនិយោគ និង

(vi) ពិនិត្យលទ្ធភាព អំពីកិច្ចព្រមព្រៀងអាស៊ាន ស្តីអំពីការមិនយកពន្ធត្រួត ។

ឧបសម្ព័ន្ធ II

## ក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីអំពីតំបន់វិនិយោគអាស៊ាន

## កម្មវិធីជំរុញនិងផ្សព្វផ្សាយ (Promotion Awareness Programme)

ពាក់ព័ន្ធនឹងកម្មវិធីជំរុញ និងផ្សព្វផ្សាយ ប្រទេសសមាជិកត្រូវ

១- រៀបចំការងារជំរុញការវិនិយោគតាមរយៈការធ្វើសិក្ខាសាលា ទស្សនៈកិច្ច សំរាប់វិនិយោគិននៃប្រទេសនាំមូលធនចេញ ជំរុញគំរោងរួមពិសេសនានាដោយមានការចូលរួមយ៉ាងសកម្មពីវិស័យអាជីវកម្ម ។

២- ធ្វើការពិគ្រោះយោបល់ជាប្រចាំ រវាងភ្នាក់ងារវិនិយោគក្នុងប្រទេសសមាជិកអំពីកិច្ចការវិនិយោគ ។

៣-រៀបចំកម្មវិធីបណ្តុះបណ្តាលវិនិយោគសំរាប់មន្ត្រីភ្នាក់ងារវិនិយោគក្នុងអាស៊ាន

៤-ផ្លាស់ប្តូរពត៌មានអំពីវិស័យនានា ដែលប្រទេសសមាជិកចង់ជំរុញអោយមានការវិនិយោគមកពីប្រទេសសមាជិកដទៃទៀត និងផ្តួចផ្តើមគំនិតកិច្ចការជំរុញ និង

៥-ពិនិត្យលទ្ធផលដែលភ្នាក់ងារវិនិយោគនៃប្រទេសសមាជិកមួយអាចជួយប្រទេសសមាជិកមួយទៀត ក្នុងការគាំទ្រសកម្មភាពជំរុញការវិនិយោគ ។

ឧបសម្ព័ន្ធ III

## ក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីអំពីតំបន់វិនិយោគអាស៊ាន

## កម្មវិធីសេរីកម្មរបបវិនិយោគ (Liberalization Programme)

ពាក់ព័ន្ធនឹងកម្មវិធីសេរីកម្មរបបវិនិយោគប្រទេសសមាជិកត្រូវៈ

១-ដាក់ឧបសគ្គ ការកាត់បន្ថយ និងលុបបំបាត់វិធានការ ដែលរឹតត្បិតការធ្វើវិនិយោគ និងពិនិត្យជាប្រចាំលើរបបវិនិយោគ ដើម្បីធ្វើសេរីភាវូបនីយកម្មបន្ថែមទៀត ។ក្នុងបរិបទនេះ ប្រទេសជាសមាជិកអាចចាត់វិធានការធ្វើសេរីភាវូបនីយកម្ម ដែលក្នុងចំណោមនោះមានៈ

- វិធាន បទដ្ឋាន និងនយោបាយដែលពាក់ព័ន្ធនឹងការវិនិយោគ
- បែបបទនៃការទទួលអាជ្ញាប័ណ្ណ
- បែបបទនៃការទទួលហិរញ្ញប្បទានក្នុងស្រុក
- បែបបទសំរួលការទូទាត់ ការផ្ទេរប្រាក់ និងការដក និងបង្វែរប្រាក់ចំណេញដោយវិនិយោគិន

២- ចាត់វិធានការអនុវត្តផែនការសកម្មភាពផ្ទាល់ខ្លួនដើម្បីៈ

- ផ្តល់នូវប្រត្តិកម្មជាតិ ដល់វិនិយោគិនអាស៊ាននៅឆ្នាំ២០១០ និងវិនិយោគិនទាំងអស់នៅឆ្នាំ២០២០ ស្របតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ និង
- បើកចំហរគ្រប់វិស័យសំរាប់ការវិនិយោគអោយវិនិយោគិនអាស៊ាននៅឆ្នាំ២០១០ និងអោយវិនិយោគិនទាំងអស់នៅឆ្នាំ២០២០ ស្របតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

៣-ជំរុញអោយមានការលំហូរដោយសេរីនូវមូលធន កំលាំងពលកម្មជំនាញ និងបច្ចេកវិទ្យាទំនើបនៅក្នុងចំណោមប្រទេសជាសមាជិក។